# ក

# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៩-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៤៩០ស្តីពីការផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃជូនមន្ត្រីរាជការចំនួន ៥៧ រូប ៣៣៧៧

០៩-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៤៩១ ស្តីពីការផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃជូនមន្ត្រីរាជការចំនួន ១៧ រូប ៣៣៨២

០៩-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៤៩២ ស្តីពីការតម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយទោជូននាយ នគរបាល ជាតិជាន់ខ្ពស់ក្រសួងមហាផ្ទៃចំនួន ០២ រូប ៣៣៨៥

០៩-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៤៩៥ ស្តីពីការតែងតាំងឯកឧត្តម **តាត់ លីហុក** ជាទីប្រឹក្សាក្រសួងពិតមាន មានឋានៈស្មើអគ្គនាយក ៣៣៨៦

០៩-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៤៩៦ ស្តីពីការតែងតាំងឥស្សរជនចំនួន ០៣រូបជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ៣៣៨៧

១៣-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៥១២ ស្តីពីការតម្លើងឋានៈលោកជំទាវចំនួន ០៤ រូប ជាទីប្រឹក្សាអមព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រមានឋានៈស្មើរដ្ឋលេខាធិការ ៣៣៨៨


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


១៩-៥-២០០៩ -អនុក្រឹត្យលេខ ៧៥ អនក្រ.បក ស្តីពីរបបឧបត្ថម្ភគោលនយោបាយចំពោះមន្ត្រីនគរបាល ពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និង ពិការ ៣៣៨៩

១៨-៥-២០០៩ -អនុក្រឹត្យលេខ ៦៥៥ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣៣៩៨

១៨-៥-២០០៩ -អនុក្រឹត្យលេខ ៦៥៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៣៩៩

១៨-៥-២០០៩ -អនុក្រឹត្យលេខ ៦៥៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៤០១

១៨-៥-២០០៩ -អនុក្រឹត្យលេខ ៦៥៨ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣៤០២

១៨-៥-២០០៩ -អនុក្រឹត្យលេខ ៦៥៩អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣៤០៣

១៨-៥-២០០៩ -អនុក្រឹត្យលេខ ៦៦០អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៤០៤

១៨-៥-២០០៩ -អនុក្រឹត្យលេខ ៦៦១អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ៣៤០៥

១៨-៥-២០០៩ -អនុក្រឹត្យលេខ ៦៦២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៤០៧

១៨-៥-២០០៩ -អនុក្រឹត្យលេខ ៦៦៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៤០៨

១៨-៥-២០០៩ -អនុក្រឹត្យលេខ ៦៦៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៣៤១០

១៨-៥-២០០៩ -អនុក្រឹត្យលេខ ៦៦៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៣៤១៧

១៨-៥-២០០៩ -អនុក្រឹត្យលេខ ៦៦៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៤២២


## ២-សេចក្តីសំរេច


២០-៥-២០០៩ - សេចក្តីម្រេចលេខ ៣១ សសរ ស្តីពីការជ្រើសរើសពលទាហាន ៣៤២៤


# III-ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


២៣-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥២៤៥ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប្រ៊ោន អាគអេទិន រីសេស ខូ អិលធីឌី** ៣៤២៥

២៣-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥២៤៦ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ័រយូ(ខេមបូឌា) វ៉ាប់ប៊ើរ** ៣៤២៧

២៣-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥២៤៧ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ អេ ដាប់ប៊ែលយូ(ខេមបូឌា)** ៣៤២៩

២៣-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥២៦១ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌី ប៊ូ លានហេង(ខេមបូឌា)** ៣៤៣១

២៣-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥២៦២ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ណាហ្គារ៉ា ខមមើសល សេនធ័រ &រីហ្សត** ៣៤៣៣

២៣-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥២៦៣ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាយ.ចី.អាយ.អេស** ៣៤៣៥

២៣-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥២៦៤ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិន យូ អូ** ៣៤៣៧

២៣-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥២៦៥ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ិនវេសមេន ឌី.ធី.** ៣៤៣៩

២៥-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥២៧២ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផាសាតេល ស៊ីស្ទឹម** ៣៤៤១

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៩/៤៩០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME du CAMBODGE
LE MINISTRE DU PALAIS ROYAL

# ត្រាស់បង្គាប់

**មាត្រា ១.-**

ត្រូវបានផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ជូនមន្ត្រីរាជការចំនួន **៥៧រូប** ដូចមានរាយនាមខាងក្រោម :

**ក-ឋានន្តរសក្តិ វរមន្ត្រី ចំនួន ១៩រូប :**

| | | | |
|---|---|---|---|
| ១- | លោកស្រី ឌួច សារ៉ុម | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៦ |
| ២- | លោកស្រី អេង គីមនាង | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៦ |
| ៣- | លោក អ៊ុង ម៉េងហួរ | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៦ |
| ៤- | លោក សុខ្ខ សឹន | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៧ |
| ៥- | លោកស្រី នូ សុវណ្ណនី | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៧ |
| ៦- | លោក អ៊ុត សំអន | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៧ |
| ៧- | លោក ចុង ផែត | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៧ |
| ៨- | លោក អ៊ុំ គាន់សុផល | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៨ |
| ៩- | លោកស្រី ពៅ សុភាព | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៨ |
| ១០- | លោកស្រី យស ថានារី | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៨ |
| ១១- | លោកស្រី នួម សុគន្ធណា | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៨ |
| ១២- | លោកស្រី ស៊ឹម ម៉ារី | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៨ |
| ១៣- | លោក អៀង អូននី | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៩ |
| ១៤- | លោក ហេង វណ្ណា | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ១០ |
| ១៥- | លោក សាយ សុជាតិ | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ១០ |
| ១៦- | លោកស្រី ឯម ផលាមុនី | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ១០ |
| ១៧- | លោកស្រី គង់ ស៊ីផា | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ១០ |
| ១៨- | លោកស្រី ឯក សុវណ្ណតារៈ | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ១០ |
| ១៩- | លោក ថង សាវុន | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ១០ |

**ខ-ឋានន្តរសក្តិ អនុមន្ត្រី ចំនួន ៣៨រូប :**

| | | | |
|---|---|---|---|
| ១- | លោក តេ អ៊ឹម | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ២- | លោក ហង្ស គីមញៀន | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៦ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| | | | | |
|---|---|---|---|---|
| ៣- | លោក | ហាក់ ម៉ូទសេង | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ៤- | លោក | ជឿន ជាន | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ៥- | លោក | សួន ញ៉ាក | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ៦- | លោក | ជា យឿង | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ៧- | លោក | នាង សិន | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ៨- | លោក | ហ៊ុយ ស៊ីធឿន | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ៩- | លោក | ឌួន សុខ | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ១០- | លោក | ស៊ីម វណ្ណា | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ១១- | លោក | ហុក រិន | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ១២- | លោក | អ៊ីម ថន | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ១៣- | លោក | អ៊ូ សុខន | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ១៤- | លោក | ជា សុផាត | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ១៥- | លោក | តូ សំអាត | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ១៦- | លោក | រ័ត្ន ជុំ | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ១៧- | លោក | ឃ៊ាង យឿត | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ១៨- | លោក | ប៊ូរ កែវសុវណ្ណ | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ១៩- | លោក | លី វិទ្ធ | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ២០- | លោក | នង ជារិទ្ធ | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ២១- | លោក | សាក់ សុន | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ២២- | លោក | អ៊ុម ស៊ីណាត | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៨ |
| ២៣- | លោក | ហ៊ុល ចំន្ទថូ | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៨ |
| ២៤- | លោក | ឆេ ឈីវ | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៨ |
| ២៥- | លោក | សម ណេង | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៨ |
| ២៦- | លោក | ស៊ិញ ស៊ុន | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៨ |
| ២៧- | លោក | ម៉ៅ ហុន | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ១០ |
| ២៨- | លោក | ឃិន សាវ៉េន | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ១០ |
| ២៩- | លោក | ម៉ៅ គីមឡុង | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ១២ |
| ៣០- | លោក | ឃី ឈឿន | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ១២ |
| ៣១- | លោក | សួន គឿន | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ១២ |
| ៣២- | លោក | រស់ ហេង | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ១២ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

| | | | |
|---|---|---|---|
| ៣៣- | លោក **សូម សារិត** | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ១២ |
| ៣៤- | លោក **ហ៊ី ធូក** | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ១៣ |
| ៣៥- | លោក **ស្រេង ស្រ៊ាង** | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ៣៦- | លោក **ឃូ ពៅ** | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ៣៧- | លោក **លី សុវណ្ណារិទ្ធ** | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ១៤ |
| ៣៨- | លោក **ឈឹម ខឿ** | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ១៤ ។ |

**មាត្រា ២.-**

ត្រូវបានផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ជូនមន្ត្រីរាជការចំនួន **១៥រូប** ដូចមានរាយនាម ខាងក្រោម :

**ក-ឋានន្តរសក្តិ វរមន្ត្រី ចំនួន ១២រូប :**

| | | | |
|---|---|---|---|
| ១- | លោកស្រី **សួស សារ៉ម** | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៦ |
| ២- | លោកស្រី **កែវ សាមឿន** | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៦ |
| ៣- | លោក **អ៊ុន សំអុល** | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៦ |
| ៤- | កញ្ញា **ជោក សុខ្ញា** | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៦ |
| ៥- | លោកស្រី **សា ចាន់ហ៊ាង** | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៧ |
| ៦- | លោកស្រី **អ៊ិត យុត** | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៨ |
| ៧- | លោកស្រី **គង សោភ័ធន** | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៨ |
| ៨- | លោក **លួន អាន** | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៨ |
| ៩- | លោក **សំ ប៊ុណ្ណារិន** | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ១០ |
| ១០- | លោក **ឡាយ វណ្ណៈ** | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ១០ |
| ១១- | លោកស្រី **ជុក សុផានី** | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ១០ |
| ១២- | លោក **សង់ វិហា** | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ១០ |

**ខ-ឋានន្តរសក្តិ អនុមន្ត្រី ចំនួន ០៣រូប :**

| | | | |
|---|---|---|---|
| ១- | លោក **អ៊ុក ឡាយ** | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ១០ |
| ២- | លោក **គង់ ស្រ៊ុន** | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ១២ |
| ៣- | លោក **ជា ចាន់លី** | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ១៣ ។ |

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

**មាត្រា ៣.-**

ត្រូវបានបញ្ចូលលោក **ម៉ែន ទិមុល** ទៅក្នុងឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ៧ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៩ល.០៩០៥.៤៩៣

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០០៩*

លេខ : ៤៤៦ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៩/៤៩២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

## ត្រាស់បង្គាប់

**មាត្រា ១.-**

ត្រូវបានផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ នូវមន្ត្រីរាជការចំនួន ១៧រូប ទៅតាមលំដាប់ឋានន្តរសក្តិ ដូចមានរាយនាមខាងក្រោម :

**ក.ឋានន្តរសក្តិ ឧត្តមមន្ត្រី ចំនួន ០៦រូប :**

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម ឡូយ សុផាត | ឋានន្តរសក្តិ ឧត្តមមន្ត្រី | ថ្នាក់លេខ ១ |
| ២- | ឯកឧត្តម អ៊ី ឈាន | ឋានន្តរសក្តិ ឧត្តមមន្ត្រី | ថ្នាក់លេខ ២ |
| ៣- | ឯកឧត្តម ម៉ែន អ៊ាន | ឋានន្តរសក្តិ ឧត្តមមន្ត្រី | ថ្នាក់លេខ ៣ |
| ៤- | ឯកឧត្តម ថាំ សាន្ត | ឋានន្តរសក្តិ ឧត្តមមន្ត្រី | ថ្នាក់លេខ ៣ |
| ៥- | ឯកឧត្តម ចាន់ យឿន | ឋានន្តរសក្តិ ឧត្តមមន្ត្រី | ថ្នាក់លេខ ៣ |
| ៦- | ឯកឧត្តម ស ថាវី | ឋានន្តរសក្តិ ឧត្តមមន្ត្រី | ថ្នាក់លេខ ៤ |

**ខ.ឋានន្តរសក្តិ វរមន្ត្រី ចំនួន ០៣រូប :**

| | | | |
|---|---|---|---|
| ១- | លោក ភង សំអឿន | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៤ |
| ២- | លោក យឹម ផាន់ណា | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៤ |
| ៣- | លោកស្រី ភែច សាវឿន | ឋានន្តរសក្តិ វរមន្ត្រី | ថ្នាក់លេខ ៥ |

**គ.ឋានន្តរសក្តិ អនុមន្ត្រី ចំនួន ០៨រូប :**

| | | | |
|---|---|---|---|
| ១- | លោក យឹម ឡាំង | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ២- | លោក គឹម អាន | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ៣- | លោក សៀវ សាធាន | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៦ |
| ៤- | លោក ហង្ស ស៊ីធីម | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៧ |
| ៥- | លោក ផាន់ សារឿន | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៨ |
| ៦- | លោក ឡូ សាវុធ | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ៨ |
| ៧- | លោក សាំង សុភៈវិចិត្រ | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ១៣ |
| ៨- | លោក ទ៉ោ ម៉េងជ្រួន | ឋានន្តរសក្តិ អនុមន្ត្រី | ថ្នាក់លេខ ១៣ ។ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣៩ល.០៩០៥.៤៩៤

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០០៩*

លេខ: ៤៥០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៩/៤៩៧

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០០១ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ឯក ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០២ រូប ដូចមានរាយនាមខាងក្រោម :

១-ឧត្តមសេនីយ៍ត្រី ជា សុគន្ធា អត្តលេខ ០១៥២៨ អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ។

២-ឧត្តមសេនីយ៍ត្រី ចៅ ឥត្ថិ អត្តលេខ ៥៨៧៦២ ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រ៧.០៩០៥.៤៩៥

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០០៩*

លេខ : ៤៥២ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៩/៤៩៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **គាត់ លីហុក** ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល.០៩០៥.៤៩៩

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០០៩*

លេខ : ៤៤៦. ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០០៩
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៩/៤៩៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឥស្សរជនចំនួន ០៣ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោម :

- ឯកឧត្តម **លូ រ៉ាមីន** មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន
- ឯកឧត្តម **ម៉ឹក ដារ៉ា** មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
- ឯកឧត្តម **ស៊ាង ប៊ុនលាង** មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៥០៥.៤៩៩

លេខ : ៤៥៤ ច.ល
ជម្រាបចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៩
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០០៩*

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៩/៥១២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

តម្លើងឋានៈលោកជំទាវ ចំនួន ០៤ រូប ជា **ទីប្រឹក្សាអមព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ**
មានឋានៈស្មើ **រដ្ឋលេខាធិការ** ៖

១- លោកជំទាវ ឡាយ ណាច
២- លោកជំទាវ សុខ សូផៃ
៣- លោកជំទាវ តាន់ ម៉េងហួយ
៤- លោកជំទាវ ចាន់ សំដារិទ្ធ

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

៣៩៧.០៩០៥.៥១៥

បានប្រថាប់ព្រះរាជលញ្ចករហើយ

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៩*

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
លេខ ៖ ០០០៣//០៩ រ.ចច
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩
សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីង្គារ
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង

LE MINISTRE DU PALAIS

គង់ សំអុល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# របបឧបត្ថម្ភគោលនយោបាយចំពោះមន្ត្រីនគរបាល ពលី មរណៈ បន្តស្លាប់ បាត់ខ្លួន និងពិការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨ /១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស /៩៤ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់អំពីរបបឧបត្ថម្ភគោលនយោបាយចំពោះមន្ត្រីនគរបាលជាតិ ដែលបានពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ ÷

- មន្ត្រីនគរបាលពលី សំដៅដល់មន្ត្រីនគរបាលជាតិដែលបាត់បង់ជីវិតនៅពេលដែលបាន ទទួលបញ្ជាបំពេញបេសកកម្ម ហ្វឹកហាត់មុខជំនាញគ្រោះថ្នាក់បំផុត ធ្វើការពិសោធដ៏មានគ្រោះថ្នាក់ និងដោយសារគ្រោះថ្នាក់ធម្មជាតិក្នុងតំបន់គ្រោះថ្នាក់

- មន្ត្រីនគរបាលមរណៈ សំដៅដល់មន្ត្រីនគរបាលជាតិដែលបំពេញភារកិច្ចក្នុងតំបន់ធម្មតា ហើយត្រូវទទួលគ្រោះថ្នាក់បាត់បង់ជីវិតដោយសារការងារទាំងនោះ ឬដោយសារជំងឺ

- មន្ត្រីនគរបាលបង្កស្លាប់ សំដៅដល់មន្ត្រីនគរបាលជាតិដែលបានបាត់បង់ជីវិតដោយធ្វើ អត្តឃាត ឬដោយសារបង្កគ្រោះថ្នាក់ដល់បាត់បង់ជីវិតដោយផ្ទាល់ ឬដោយប្រយោលដែលល្មើសច្បាប់ វិន័យ និងបទបញ្ជា

- មន្ត្រីនគរបាលបាត់ខ្លួន សំដៅដល់មន្ត្រីនគរបាលជាតិដែលបានទទួលបញ្ជាបំពេញ បេសកកម្មហ្វឹកហាត់មុខជំនាញឯកទេស និងធ្វើការពិសោធប្រកបដោយគ្រោះថ្នាក់ ហើយត្រូវបាត់ខ្លួន ដែលពុំអាចសន្និដ្ឋានបានថាស្លាប់ ឬរស់ រត់ចោលជួរ ឬត្រូវជនល្មើសចាប់

- មន្ត្រីនគរបាលពិការ សំដៅដល់មន្ត្រីនគរបាលជាតិដែលបាត់បង់សរីរាង្គណាមួយ ឬច្រើន នៅលើរាងកាយ ក្នុងពេលដែលបានទទួលបញ្ជាបំពេញបេសកកម្មហ្វឹកហាត់មុខជំនាញគ្រោះថ្នាក់បំផុត ធ្វើការពិសោធដ៏មានគ្រោះថ្នាក់ និងដោយសារគ្រោះថ្នាក់ធម្មជាតិក្នុងតំបន់គ្រោះថ្នាក់ ឬក្នុងពេល បំពេញការងារធម្មតា ។

# ជំពូកទី ២
# ប្រភេទមន្ត្រីនគរបាលពិការ

**មាត្រា ៣.-**

មន្ត្រីនគរបាលពិការមាន២ប្រភេទគឺ ៖

១- មន្ត្រីនគរបាលពិការប្រភេទ "ក" ជាមន្ត្រីនគរបាលជាតិដែលមានជំងឺរបួសក្នុងពេលទទួលបញ្ជាបំពេញបេសកកម្មហ្វឹកហាត់មុខជំនាញគ្រោះថ្នាក់បំផុត ធ្វើការពិសោធដ៏មានគ្រោះថ្នាក់ និងដោយសារគ្រោះថ្នាក់ធម្មជាតិក្នុងតំបន់គ្រោះថ្នាក់ ត្រូវបានចែកចេញជា ៤ថ្នាក់ ៖

- ថ្នាក់ទី១ មានកំរិតបាត់បង់សមត្ថភាពការងារលើសពី ៨០ (ប៉ែតសិប) ភាគរយ
- ថ្នាក់ទី២ មានកំរិតបាត់បង់សមត្ថភាពការងារលើសពី ៦០ (ហុកសិប) ភាគរយ
- ថ្នាក់ទី៣ មានកំរិតបាត់បង់សមត្ថភាពការងារលើសពី៤០ (សែសិប) ភាគរយ
- ថ្នាក់ទី៤ មានកំរិតបាត់បង់សមត្ថភាពការងារលើសពី ២០ (ម្ភៃ) ភាគរយ

២- មន្ត្រីនគរបាលពិការប្រភេទ "ខ" ជាមន្ត្រីនគរបាលជាតិដែលមានជំងឺរបួសក្នុងពេលបំពេញការងារធម្មតា ត្រូវបានចែកចេញជា ៣ថ្នាក់ ៖

- ថ្នាក់ទី១ មានកំរិតបាត់បង់សមត្ថភាពការងារលើសពី ៨០ (ប៉ែតសិប) ភាគរយ
- ថ្នាក់ទី២ មានកំរិតបាត់បង់សមត្ថភាពការងារលើសពី ៦០ (ហុកសិប) ភាគរយ
- ថ្នាក់ទី៣ មានកំរិតបាត់បង់សមត្ថភាពការងារលើសពី ៤០ (សែសិប) ភាគរយ។

**មាត្រា ៤.-**

មន្ត្រីនគរបាលពិការប្រភេទ "ក" នៅពេលទទួលមរណៈភាព ត្រូវបានទទួលស្គាល់ជាមន្ត្រីនគរបាលពលី ។

មន្ត្រីនគរបាលពិការប្រភេទ "ក" នៅពេលរងរបួសបន្ថែមទៀតដោយសារទទួលបញ្ជាបំពេញបេសកកម្ម ឬបំពេញការងារធម្មតា ត្រូវបានពិនិត្យវាយតម្លៃថ្នាក់ពិការឡើងវិញ។

**មាត្រា ៥.-**

មន្ត្រីនគរបាលពិការប្រភេទ "ខ" នៅពេលទទួលមរណៈភាព ត្រូវបានទទួលស្គាល់ជាមន្ត្រីនគរបាលមរណៈ។

មន្ត្រីនគរបាលពិការប្រភេទ "ខ" នៅពេលរងរបួសបន្ថែមទៀតដោយសារបំពេញបេសកកម្ម ត្រូវបានទទួលស្គាល់ជាមន្ត្រីនគរបាលពិការប្រភេទ "ក" វិញ។

**មាត្រា ៦.-**

ការវាយតម្លៃប្រភេទថ្នាក់ពិការ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាវាយតម្លៃមួយរបស់ក្រសួងមហាផ្ទៃ ដោយផ្អែកតាមប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ជំពូកទី ៣
## របបឧបត្ថម្ភចំពោះមន្ត្រីនគរបាលពលី មរណៈ បន្តស្លាប់ បាត់ខ្លួន និងពិការ

**មាត្រា ៧.-**

មន្ត្រីនគរបាលពលីត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចខាងក្រោម ៖

- ប្រាក់ឧបត្ថម្ភស្មើនឹងទឹកប្រាក់ចំនួន ៩ (ប្រាំបួន)ខែ នៃប្រាក់បៀវត្សរ៍សរុបប្រចាំខែចុងក្រោយរបស់មន្ត្រីនគរបាលពលី ជូនដល់គ្រួសារសព ឬអង្គភាពដែលទទួលបន្ទុករៀបចំធ្វើបុណ្យបូជា ឬបញ្ចុះសព

- ប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនគ្រួសារសព ស្មើនឹងទឹកប្រាក់ចំនួន ១៥ (ដប់ប្រាំ)ខែ នៃប្រាក់បៀវត្សរ៍សរុបប្រចាំខែចុងក្រោយរបស់មន្ត្រីនគរបាលពលី

- ប្រាក់ឧបត្ថម្ភជំនួយគ្រួសារជាប្រចាំខែជូនដល់ប្រពន្ធ ឬប្តី កូនបង្កើត ឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលរបស់មន្ត្រីនគរបាលពលី តាមប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការឯកភាពពីរាជរដ្ឋាភិបាល។

**មាត្រា ៨.-**

មន្ត្រីនគរបាលមរណៈត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចខាងក្រោម ៖

- ប្រាក់ឧបត្ថម្ភស្មើនឹងទឹកប្រាក់ចំនួន ៧ (ប្រាំពីរ) ខែ នៃប្រាក់បៀវត្សរ៍សរុបប្រចាំខែចុងក្រោយរបស់មន្ត្រីនគរបាលមរណៈជូនដល់គ្រួសារសព ឬអង្គភាពដែលទទួលបន្ទុករៀបចំធ្វើបុណ្យបូជា ឬបញ្ចុះសព

- ប្រាក់ឧបត្ថម្ភមួយលើកដំបូងជូនគ្រួសារសពស្មើនឹងទឹកប្រាក់ចំនួន ១២ (ដប់ពីរ)ខែ នៃប្រាក់បៀវត្សរ៍សរុបប្រចាំខែចុងក្រោយរបស់មន្ត្រីនគរបាលមរណៈ

- ប្រាក់ឧបត្ថម្ភជំនួយគ្រួសារជាប្រចាំខែជូនដល់ប្រពន្ធ ឬប្តី កូនបង្កើត ឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលរបស់មន្ត្រីនគរបាលមរណៈតាមប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការឯកភាពពីរាជរដ្ឋាភិបាល។

**មាត្រា ៩.-**

មន្ត្រីនគរបាលបង្កស្លាប់ត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចខាងក្រោម ÷

- ប្រាក់ឧបត្ថម្ភស្មើនឹងទឹកប្រាក់ចំនួន ៥ (ប្រាំ) ខែ នៃប្រាក់បៀវត្សរ៍សរុបប្រចាំខែចុងក្រោយរបស់មន្ត្រីនគរបាលបង្កស្លាប់ជូនដល់គ្រួសារសព ឬអង្គភាពដែលទទួលបន្ទុករៀបចំធ្វើបុណ្យបូជា ឬបញ្ចុះសព

- ប្រាក់ឧបត្ថម្ភមួយលើកផ្តាច់ជូនដល់គ្រួសារសពស្មើនឹងទឹកប្រាក់ចំនួន ១២(ដប់ពីរ) ខែ នៃប្រាក់បៀវត្សរ៍សរុបប្រចាំខែចុងក្រោយរបស់មន្ត្រីនគរបាលបង្កស្លាប់ ។

**មាត្រា ១០.-**

មន្ត្រីនគរបាលបាត់ខ្លួនត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចខាងក្រោម ÷

- បន្តបើកប្រាក់បៀវត្សរ៍របស់មន្ត្រីនគរបាលបាត់ខ្លួនព្រមទាំងរបបអង្ករប្រចាំខែជូនគ្រួសារ ចាប់ពីខែឆ្នាំបាត់ខ្លួនរហូតដល់គំរប់ ១២ ( ដប់ពីរ ) ខែ

- ក្រោយ ១២ ( ដប់ពីរ )ខែ គិតចាប់ពីខែឆ្នាំបាត់ខ្លួនមកនៅតែពុំឃើញវិលត្រឡប់មកវិញ ត្រូវបានកំណត់ទទួលស្គាល់ជាមន្ត្រីនគរបាលពលី ហើយគ្រួសារត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចជាមន្ត្រីនគរបាលពលីដែរ លើកលែងតែប្រាក់ឧបត្ថម្ភសំរាប់បូជា ឬបញ្ចុះសព

- ក្នុងអំឡុងពេលកំពុងទទួលប្រាក់ឧបត្ថម្ភណាមួយក្នុងចំណុចទាំងពីរខាងលើ ប្រសិនបើមន្ត្រីនគរបាលបាត់ខ្លួនបានវិលត្រឡប់មកអង្គភាពដើម ឬវិលទៅលំនៅដ្ឋានវិញ ការផ្តល់ប្រាក់ឧបត្ថម្ភត្រូវតែបញ្ឈប់ចាប់ពីខែឆ្នាំដែលមន្ត្រីនគរបាលបាត់ខ្លួននោះមានមុខ ។ ក្នុងករណីបានទទួលស្គាល់ជាមន្ត្រីនគរបាលពលីដោយបានកាត់ផ្តាច់ក្របខ័ណ្ឌចេញពីក្រសួងមហាផ្ទៃរួចហើយ ស្រាប់តែមន្ត្រីនគរបាលបាត់ខ្លួននោះបានវិលត្រឡប់មកវិញ ហើយចង់ចូលបំរើការងារបន្តទៀត ត្រូវបានបញ្ចូលក្របខណ្ឌជាថ្មីដោយទទួលឋានន្តរសក្តិ និងប្រាក់បៀវត្សរ៍ដូចមុនពេលបាត់ខ្លួន ។

**មាត្រា ១១.-**

ជនដែលមានគ្រប់លក្ខណៈសម្បត្តិអាចទទួលរបបឧបត្ថម្ភរបស់មន្ត្រីនគរបាលពលី មរណៈ បង្កស្លាប់ និងបាត់ខ្លួនរួមមាន ÷

- ឪពុក និងម្តាយបង្កើត ឬអ្នកអាណាព្យាបាលតាំងពីវ័យកុមាររបស់មន្ត្រីនគរបាលជាតិ បើសិនជាមន្ត្រីនគរបាលនោះនៅលីវ

- ប្រពន្ធ ឬប្តីរបស់មន្ត្រីនគរបាលជាតិដែលមានលិខិតអាពាហ៍ពិពាហ៍ ហើយពុំទាន់រៀបអាពាហ៍ពិពាហ៍ជាថ្មីទៀត

- កូនបង្កើតរបស់មន្ត្រីនគរបាលជាតិដែលមានសំបុត្រកំណើតអាយុក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំចុះ និងមានអាយុ ១៨ ( ដប់ប្រាំបី )ឆ្នាំឡើង ដែលមានលិខិតបញ្ជាក់កំពុងបន្តការសិក្សាហើយពុំមានទទួលអាហារូបករណ៍ ឬកូនដែលពិការភាពមានលិខិតបញ្ជាក់ត្រឹមត្រូវ

- ឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលដែលមានកូនពលី ឬមរណៈចំនួន ២ (ពីរ ) នាក់ ឡើងទៅ ត្រូវបានទទួលរបបឧបត្ថម្ភគុណតាមចំនួនកូនដែលបានពលី ឬមរណៈនោះ ។

**មាត្រា ១២.-**

ប្រាក់ឧបត្ថម្ភចំពោះមន្ត្រីនគរបាលពិការប្រភេទ "ក" មានដូចខាងក្រោម ៖

១-ក្រោយពេលព្យាបាលជំងឺរបួសជាសះស្បើយ ហើយត្រូវបានទទួលប្រាក់ឧបត្ថម្ភបំប៉នសុខភាព នៅមជ្ឈមណ្ឌលបំប៉នសុខភាពតាមរយៈពេលកំណត់ និងតាមលំដាប់ថ្នាក់ពិការ ដូចខាងក្រោម ៖

- ថ្នាក់ទី១ ត្រូវបានអនុញ្ញាតអោយឈប់សម្រាករយៈពេល ៩០ ( កៅសិប ) ថ្ងៃ
- ថ្នាក់ទី២ ត្រូវបានអនុញ្ញាតអោយឈប់សម្រាករយៈពេល ៦០ ( ហុកសិប ) ថ្ងៃ
- ថ្នាក់ទី៣ ត្រូវបានអនុញ្ញាតអោយឈប់សម្រាករយៈពេល ៤៥ ( សែសិបប្រាំ ) ថ្ងៃ
- ថ្នាក់ទី៤ ត្រូវបានអនុញ្ញាតអោយឈប់សម្រាករយៈពេល ៣០ ( សាមសិប ) ថ្ងៃ ។

២- មន្ត្រីនគរបាលពិការដែលនៅបន្តការងារក្នុងក្របខណ្ឌមន្ត្រីនគរបាលជាតិ ត្រូវបានទទួលប្រាក់ឧបត្ថម្ភជំនួយមុខរបួសជាប្រចាំខែ ដោយគិតសមាមាត្រភាគរយនៃប្រាក់បៀវត្សរ៍សរុបប្រចាំខែផ្ទាល់ខ្លួន និងតាមលំដាប់ថ្នាក់ពិការដូចខាងក្រោម ៖

- ថ្នាក់ទី១ ត្រូវបានទទួលប្រាក់របបឧបត្ថម្ភស្មើនឹង ៤៥ ( សែសិបប្រាំ ) ភាគរយ
- ថ្នាក់ទី២ ត្រូវបានទទួលប្រាក់របបឧបត្ថម្ភស្មើនឹង ៤០ ( សែសិប ) ភាគរយ
- ថ្នាក់ទី៣ ត្រូវបានទទួលប្រាក់របបឧបត្ថម្ភស្មើនឹង ៣៥ ( សាមសិបប្រាំ) ភាគរយ
- ថ្នាក់ទី៤ ត្រូវបានទទួលប្រាក់របបឧបត្ថម្ភស្មើនឹង ៣០ ( សាមសិប ) ភាគរយ ។

៣- មន្ត្រីនគរបាលពិការដែលក្រសួងមហាផ្ទៃសម្រេចអោយចេញពីក្របខណ្ឌមន្ត្រីនគរបាលជាតិ ត្រូវបានទទួលប្រាក់ឧបត្ថម្ភអតីតភាពបំរើការងារមិនលើសពី ២៤ ( ម្ភៃបួន)ខែ ដោយគិតតាមរយៈពេលបំរើការងារក្នុងក្របខណ្ឌមន្ត្រីនគរបាលជាតិក្នុង ១ ( មួយ)ឆ្នាំ ត្រូវបានទទួលប្រាក់ឧបត្ថម្ភអតីតភាពចំនួន ២ ( ពីរ) ខែ ។ ចំពោះមន្ត្រីនគរបាលពិការដែលបំរើការងារក្នុងក្របខណ្ឌមន្ត្រីនគរបាលជាតិមិនទាន់គ្រប់រយៈពេល ១ ( មួយ )ឆ្នាំ ហើយពិការ ក៏ត្រូវបានទទួលប្រាក់ឧបត្ថម្ភអតីតភាពចំនួន ២ ( ពីរ )ខែ ដែរ។

៤- មន្ត្រីនគរបាលពិការត្រូវបានទទួលប្រាក់ឧបត្ថម្ភមួយលើកដំបូង តាមលំដាប់ថ្នាក់ពិការដូចខាងក្រោម ៖

- ថ្នាក់ទី១ ត្រូវបានទទួលប្រាក់ឧបត្ថម្ភស្មើនឹងទឹកប្រាក់ចំនួន ១២ (ដប់ពីរ)ខែ នៃប្រាក់បៀវត្សរ៍សរុបប្រចាំខែចុងក្រោយរបស់មន្ត្រីនគរបាលពិការ
- ថ្នាក់ទី២ ត្រូវបានទទួលប្រាក់ឧបត្ថម្ភស្មើនឹងទឹកប្រាក់ចំនួន ១០ (ដប់) ខែ នៃប្រាក់បៀវត្សរ៍សរុបប្រចាំខែចុងក្រោយរបស់មន្ត្រីនគរបាលពិការ
- ថ្នាក់ទី៣ ត្រូវបានទទួលប្រាក់ឧបត្ថម្ភស្មើនឹងទឹកប្រាក់ចំនួន ៨ (ប្រាំបី) ខែ នៃប្រាក់បៀវត្សរ៍សរុបប្រចាំខែចុងក្រោយរបស់មន្ត្រីនគរបាលពិការ
- ថ្នាក់ទី៤ ត្រូវបានទទួលប្រាក់ឧបត្ថម្ភស្មើនឹងទឹកប្រាក់ចំនួន ៦ (ប្រាំមួយ) ខែ

នៃប្រាក់បៀវត្សរ៍សរុបប្រចាំខែចុងក្រោយរបស់មន្ត្រីនគរបាលពិការ ។

៥- ត្រូវបានបន្តបើកប្រាក់បៀវត្សរ៍សរុបប្រចាំខែ ដោយគិតតាមឋានន្តរសក្តិចុងក្រោយ មុនពេលសម្រេចអោយចេញពីក្របខណ្ឌមន្ត្រីនគរបាលជាតិ និងចំនួនកូននៅក្នុងបន្ទុកជាក់ស្តែងរបស់នគរបាលពិការ ។

៦- មន្ត្រីនគរបាលពិការដែលរស់នៅក្នុងមណ្ឌលជនពិការ និងមន្ត្រីនគរបាលពិការដែលផ្ទេរចេញពីក្របខណ្ឌមន្ត្រីនគរបាលជាតិ ត្រូវបានទទួលប្រាក់ឧបត្ថម្ភជំនួយមុខរបួសជាប្រចាំខែដោយគិតសមាមាត្រ ភាគរយនៃប្រាក់បៀវត្សរ៍សរុបប្រចាំខែផ្ទាល់ខ្លួន និងតាមលំដាប់ថ្នាក់ពិការដូចខាងក្រោម ÷

-ថ្នាក់ទី១ត្រូវបានទទួលប្រាក់របបឧបត្ថម្ភជំនួយមុខរបួសស្មើនឹង ១០០ ( មួយរយ) ភាគរយ

- ថ្នាក់ទី២ ត្រូវបានទទួលប្រាក់របបឧបត្ថម្ភជំនួយមុខរបួសស្មើនឹង ៨០(ប៉ែតសិប ) ភាគរយ

- ថ្នាក់ទី៣ ត្រូវបានទទួលប្រាក់របបឧបត្ថម្ភជំនួយមុខរបួសស្មើនឹង ៦០(ហុកសិប ) ភាគរយ

- ថ្នាក់ទី៤ ត្រូវបានទទួលប្រាក់របបឧបត្ថម្ភជំនួយមុខរបួសស្មើនឹង ៤០(សែសិប) ភាគរយ។

៧- មន្ត្រីនគរបាលពិការថ្នាក់ទី១ ត្រូវបានទទួលរបបឧបត្ថម្ភអ្នកបំរើផ្ទាល់ខ្លួន ១នាក់ ជាប្រចាំខែ រហូតដល់មន្ត្រីនគរបាលពិការនោះស្លាប់ ដែលមានទឹកប្រាក់ស្មើនឹងប្រាក់បៀវត្សរ៍សរុបអប្បបរមាផ្ទាល់ខ្លួនរបស់មន្ត្រីនគរបាលជាតិដែលមានឋានន្តរសក្តិពលបាលត្រី។

៨- ត្រូវបានទទួលរបបឧបត្ថម្ភចិញ្ចឹមប្រពន្ធ ឬប្តី កូន ដូចពេលកំពុងបំរើការងារដែរ ។

**មាត្រា ១៣ .-**

ប្រាក់ឧបត្ថម្ភចំពោះមន្ត្រីនគរបាលពិការប្រភេទ "ខ" មានដូចខាងក្រោម ÷

១- មន្ត្រីនគរបាលពិការដែលក្រសួងមហាផ្ទៃសម្រេចអោយចេញពីក្របខណ្ឌមន្ត្រីនគរបាលជាតិ ត្រូវបានទទួលប្រាក់ឧបត្ថម្ភអតីតភាពបំរើការងារមិនលើសពី ៨ ( ប្រាំបី)ខែ ដោយគិតតាមរយៈពេលបំរើការងារក្នុងក្របខណ្ឌមន្ត្រីនគរបាលជាតិក្នុង ១ ( មួយ ) ឆ្នាំ ត្រូវបានទទួលប្រាក់ឧបត្ថម្ភអតីតភាពចំនួន ២ (ពីរ) ខែ ។ ចំពោះមន្ត្រីនគរបាលពិការដែលបំរើការងារក្នុងក្របខណ្ឌមន្ត្រីនគរបាលជាតិមិនទាន់គ្រប់រយៈពេល ១ (មួយ) ឆ្នាំ ហើយពិការ ក៏ត្រូវបានទទួលប្រាក់ឧបត្ថម្ភអតីតភាពចំនួន ២ខែ (ពីរខែ) ដែរ ។

២- ត្រូវបានទទួលប្រាក់ឧបត្ថម្ភជាប្រចាំខែ ដោយគិតសមាមាត្រភាគរយនៃប្រាក់បៀវត្សរ៍សរុប ចុងក្រោយផ្ទាល់ខ្លួន និងតាមលំដាប់ថ្នាក់ពិការដូចខាងក្រោម ÷

-ថ្នាក់ទី១ ត្រូវបានទទួលប្រាក់របបឧបត្ថម្ភស្មើនឹង ៩០ (កៅសិប ) ភាគរយ

-ថ្នាក់ទី២ ត្រូវបានទទួលប្រាក់របបឧបត្ថម្ភស្មើនឹង ៨០ (ប៉ែតសិប ) ភាគរយ

- ថ្នាក់ទី៣ ត្រូវបានទទួលប្រាក់របបឧបត្ថម្ភស្មើនឹង ៧០ (ចិតសិប ) ភាគរយ ។

៣- ត្រូវបានទទួលរបបឧបត្ថម្ភចិញ្ចឹមប្រពន្ធ ឬប្តី កូន ដូចពេលកំពុងបំរើការងារដែរ ។

**មាត្រា ១៤ .-**

មន្ត្រីនគរបាលពិការទាំងពីរប្រភេទគ្រប់លំដាប់ថ្នាក់ ត្រូវបានទទួលប្រាក់ឧបត្ថម្ភបន្ថែម ដូចខាងក្រោម ÷

១- រាល់ថ្ងៃបុណ្យចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ និងថ្ងៃបុណ្យរំលឹកគុណមន្ត្រីនគរបាលពលី ពិការ (កំណត់យកថ្ងៃបុណ្យភ្ជុំបិណ្ឌ ) ត្រូវបានទទួលប្រាក់ឧបត្ថម្ភដូចមន្ត្រីរាជការដែលកំពុងបំរើការងារដែរ ។

២-ពេលមានជំងឺរបួស ឬពេលរបួសសើរើត្រូវបានទទួលការសង្គ្រោះព្យាបាលរហូតជាសះស្បើយ នៅតាមមន្ទីរពេទ្យរដ្ឋដោយឥតគិតថ្លៃ ។

៣- ត្រូវបានរដ្ឋជួយស្តារលទ្ធភាពពលកម្ម កាយសម្បទា និងផ្តល់ឧបករណ៍ទ្រទ្រង់រាងកាយ ដោយឥតបង់ប្រាក់ ជួយបណ្តុះបណ្តាលមុខវិជ្ជាជីវៈ និងត្រូវបានជួយបង្កអោយមានមុខរបរសមស្រប តាមសមត្ថភាព និងលទ្ធភាពជាក់ស្តែងរបស់មន្ត្រីនគរបាលពិការ ។

៤- ចំពោះមន្ត្រីនគរបាលពិការជាស្ត្រី ត្រូវបានទទួលឧបត្ថម្ភបន្ថែមនូវការធានារ៉ាប់រងសង្គម ដូចស្ត្រីដែលកំពុងបំរើការងារមន្ត្រីរាជការដែរ។

៥-មន្ត្រីនគរបាលពិការដែលនៅបំរើការងារ ពេលគ្រប់លក្ខណៈសម្បត្តិចូលនិវត្តន៍ត្រូវបាន ទទួលប្រាក់សោធននិវត្តន៍ តាមច្បាប់កំណត់ដោយមានរួមបញ្ចូលទាំងប្រាក់ឧបត្ថម្ភជំនួយមុខរបួសជា ប្រចាំខែដូចពេលកំពុងបំរើការងារដែរ ។

## ជំពូកទី ៤
## ការទទួលខុសត្រូវលើប្រាក់ឧបត្ថម្ភចំពោះមន្ត្រីនគរបាលពលី មរណៈ បង្កស្លាប់ បាត់ខ្លួន និងពិការ

**មាត្រា ១៥ .-**

ក្រសួងមហាផ្ទៃជាអ្នកទទួលបន្ទុកដោះស្រាយនូវរាល់ការចំណាយដូចខាងក្រោម :

- ប្រាក់ឧបត្ថម្ភសំរាប់បូជា ឬបញ្ចុះសព
- ប្រាក់ឧបត្ថម្ភជូនគ្រួសារមន្ត្រីនគរបាលពលី មរណៈ និងបង្កស្លាប់មួយលើកដំបូង
- ប្រាក់ឧបត្ថម្ភជំនួយមុខរបួសដល់មន្ត្រីនគរបាលពិការនៅបំរើការងារក្នុងក្របខណ្ឌ មន្ត្រីនគរបាលជាតិ
- ប្រាក់ឧបត្ថម្ភបំប៉នសុខភាពមន្ត្រីនគរបាលពិការ

-ប្រាក់ឧបត្ថម្ភអតីតភាពការងាររបស់មន្ត្រីនគរបាលពិការ មុនពេលសំរេចអោយចេញពីក្របខណ្ឌមន្ត្រីនគរបាលជាតិ ។

**មាត្រា ១៦ .-**

ក្រៅពីរបបឧបត្ថម្ភដែលក្រសួងមហាផ្ទៃទទួលបន្ទុកដោះស្រាយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាអ្នកទទួលបន្ទុកដោះស្រាយបន្ត ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ១៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៦៥៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ប្រគេនព្រះតេជគុណ **អ៊ែន សំអុល** ព្រះចៅអធិការវត្តបារាយណ៍រង្សី ដែលបានបរិច្ចាគបច្ច័យ ជួយកសាងព្រះវិហារ និងសមិទ្ធផលជាច្រើនទៀត នៅវត្តបារាយណ៍រង្សី ស្ថិតនៅក្នុងឃុំខ្វិតធំ ស្រុកព្រៃឈរ ខេត្តកំពង់ចាម សរុបបច្ច័យចំនួន ១០៥.៩៣៩ដុល្លារ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៦៥៦ អនក្រ-បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ប្រគេន និងជូនសប្បុរសជនចំនួន០៩រូប ដែល បានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងព្រះវិហារ និងសមិទ្ធផលជាច្រើនទៀត នៅក្នុងវត្តបារាយណ៍រង្សី ស្ថិតនៅក្នុងឃុំខ្វិតធំ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ដូចមានរាយព្រះនាម និងនាមខាងក្រោម:-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **នេត ម៉ុន** | ព្រះគ្រូសូត្រស្តាំវត្តបារាយណ៍រង្សី | បច្ច័យចំនួន ១៥.៤២៦ដុល្លារ |
| ២-លោក | **សឿត តៃហួរ** | មេឃុំខ្វិតធំ | ថវិកាចំនួន ១២.១៨៥ដុល្លារ |
| ៣-ឧបាសក | **កែប ឆែម** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១១.៣៣០ដុល្លារ |
| ៤-លោក | **អ៊ឹង ឆៃស្រ៊ុន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.០២៥ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ឧបាសក | **ឆេព ហ៊ុន** | អាចារ្យវត្តបារាយណ៍រង្សី | ថវិកាចំនួន ៧.៥៨២ដុល្លារ |
| ២-ឧបាសិកា | **ស្បោង យាម់** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ថវិកាចំនួន ៦.១២០ដុល្លារ |
| ៣-ឧបាសក | **សេង ត្រាង** | គណៈកម្មការវត្តបារាយណ៍រង្សី | ថវិកាចំនួន ៦.០២៨ដុល្លារ |
| ៤-ឧបាសក | **យឹម យឿន** | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ៥.៧៣៩ដុល្លារ |

**គ_មេដាយសេរីវឌ្ឍនាបនាជាតិ :**

-អ្នកស្រី **ឡុង សុភាព** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ៣.០៧៥ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ៤ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
